# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជានៅព្រះសហគមន៍សន្តីម៉ារីម៉ាដាឡា
# ស្វាយប៉ាក ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២០
## សង្គមថ្មី

**អត្ថបទទី១៖ ព្រះប្រាជ្ញាញាណ ៦,១២-១៦**

អ្នកដែលប្រុងស្មារតីដោយនឹកដល់ព្រះប្រាជ្ញាញាណ មុខជារួចពីកង្វល់គ្រប់បែបយ៉ាងក្នុងពេលឆាប់ៗ។ ប្រាញ ៦,១៥

**អត្ថបទទី២៖ ថេស្សាឡូនិក ទី១ ៤,១៣-១៨**

ព្រះជាម្ចាស់នឹងនាំបងប្អូនដែលបានស្លាប់ទៅហើយ ឲ្យទៅនៅជាមួយព្រះអង្គ ដោយសារព្រះយេស៊ូដែរ។ ១ថស ៤,១៤

**ដំណឹងល្អ៖ ម៉ាថាយ ២៥,១-១៣**

នាងបានយកចង្កៀងទៅ មានទាំងប្រេងបង្ការផង។ មថ ២៥,៤

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ អត្ថបទគម្ពីរណែនាំឲ្យយើងត្រូវតែភ្ញាក់ស្មារតី ជាពិសេសនៅក្នុងកាលៈទេសៈនៃពិភពលោកសព្វថ្ងៃ។ ព្រះយេស៊ូមានព្រះបន្ទូលថា "**ចូរអ្នករាល់គ្នាប្រុងស្មារតី ត្បិតអ្នករាល់គ្នាពុំដឹងថាបុត្រមនុស្សនឹងមកដល់ថ្ងៃណាឬពេលណាឡើយ**"។ ព្រះយេស៊ូមានព្រះបន្ទូលអំពីព្រះអង្គផ្ទាល់ ដោយយើងមិនដឹងថាព្រះយេស៊ូយាងមកពេលណា ដើម្បីចូលនៅក្នុងដួងចិត្តរបស់យើង។ ប្រសិនបើ យើងមិនបានរៀបចំចិត្តគំនិត មិនបានរៀបចំជីវិតរបស់យើងយ៉ាងច្បាស់លាស់ នៅពេលព្រះយេស៊ូគោះទ្វារដើម្បីចូលនៅក្នុងជីវិតរបស់យើង យើងមិនអាចបើកទ្វារបានព្រោះយើងស្តាប់មិនលឺ ឬយើងខ្មាស់ដោយសារយើងមិនបានរៀបចំខ្លួន។ នៅពេលយើងដឹងមុនថា យើងមានភ្ញៀវមកលេងនោះយើងនឹងរៀបចំអស់ពីសមត្ថភាព ដើម្បីទទួលស្វាគមន៍ភ្ញៀវឲ្យបានសមរម្យ។ ជីវិតរបស់យើងត្រូវការរៀបចំជីវិត មិនមែនតែរៀបចំផ្ទះពេលយើងមានភ្ញៀវ ប៉ុន្តែផ្ទះរបស់យើងត្រូវការថែរក្សាអនាម័យជានិច្ច។ ត្រូវការរៀបចំរាល់ថ្ងៃឲ្យបានស្អាត មិនមែនយើងរៀបចំនៅពេលតែមានភ្ញៀវមកលេងយូរៗម្តង។

នៅក្នុងសម័យកូវីដ១៩ តាំងពីខែមករាមក ណែនាំឲ្យយើងភ្ញាក់ស្មារតីច្រើន មុនដំបូងយើងគិតថាមិនមែនសម្រាប់យើង គឺសម្រាប់ប្រជាជនដែលរស់នៅប្រទេសចិន នៅទ្វីបអឺរ៉ុប នៅអាមេរិក។ ប៉ុន្តែក្រោយមក វាបានរាតត្បាតមកដល់យើង **តើយើងបានត្រៀមខ្លួនឬនៅ?** សព្វថ្ងៃនៅភ្នំពេញយើងកំពុងភ័យដែរ ជាហេតុខ្ញុំអំពាវនាវឲ្យព្រះសហគមន៍យើងក្នុងភូមិភាគភ្នំពេញ យកចិត្តទុកដាក់តាមការណែនាំរបស់ក្រសួងសុខាភិបាល។ មួយរយៈពេលចុងក្រោយនេះ យើង

សប្បាយចិត្តដោយគិតថា ជំងឺកូវីដ១៩ចាប់ផ្តើមស្ងាត់ទៅៗនៅប្រទេសកម្ពុជាយើង។ ប៉ុន្តែដោយសារមានរដ្ឋមន្ត្រីម្នាក់មកពីប្រទេសហុងគ្រី បានមកប្រទេសកម្ពុជាហើយគាត់បានធ្វើតេស្តទៅឃើញមានជំងឺកូវីដ១៩។ ដូច្នេះ ណែនាំឲ្យយើងរដ្ឋាភិបាលក៏ដូចជាប្រជាជនយើងភ័យខ្លាចក្នុងការឆ្លងជំងឺដ៏សាហាវមួយនេះជាថ្មីម្តងទៀត។

នៅក្នុងគម្ពីរដំណឹងល្អថ្ងៃនេះយើងមានស្ត្រី១០នាក់ ក្នុងនោះមានស្ត្រី៥នាក់ដែលមានប្រាជ្ញា ដោយបានខិតខំយកចិត្តទុកដាក់ ខិតខំរៀបចំជានិច្ច និងមានស្ត្រី៥នាក់ទៀតដែលគ្មានប្រាជ្ញា ចេះតែគិតពីការសប្បាយៗតាមកាលៈទេសៈ។ នៅពេលស្វាមីកំពុងធ្វើដំណើរត្រលប់មកវិញ ស្ត្រី៥នាក់ដែលមានប្រាជ្ញាបានស្វាគមន៍ប្តីយ៉ាងល្អ រីឯស្ត្រី៥នាក់ដែលគ្មានប្រាជ្ញាមិនបានរៀបចំដើម្បីស្វាគមន៍ប្តីបានល្អទេ ដោយសារមិនបានត្រៀមខ្លួនមុន។ ដូច្នេះ សម្រាប់យើងដែលជាគ្រីស្តបរិស័ទ យើងត្រូវពិចារណា **តើយើងជាក្រុមស្ត្រីដែលមានប្រាជ្ញា ឬយើងជាក្រុមស្ត្រីដែលគ្មានប្រាជ្ញា? តើយើងជាគ្រីស្តបរិស័ទដែលយកចិត្តទុកដាក់រៀបចំជានិច្ច ដើម្បីទទួលស្វាគមន៍ព្រះយេស៊ូដែលនឹងយាងមក ឬយើងជាគ្រីស្តបរិស័ទដែលមិនគិតអ្វីសោះ?**

ព្រះយេស៊ូយាងមករបៀបណាយើងមិនដឹងទេ ព្រះយេស៊ូអាចជាអ្នកសុំទានម្នាក់ អាចជាអ្នកជំងឺម្នាក់ អាចជាមនុស្សដែលកំពុងរងទុក្ខលំបាក អាចជាមនុស្សដែលមកសួរសុខទុក្ខយើង ឬអាចជាពេលវេលាចុងក្រោយរបស់យើង ដែលយើងមិនដឹង។ ដូច្នេះ ប្រសិនបើជីវិតរបស់យើងមិនត្រៀមជានិច្ច យើងធ្វើដូចម្តេចដើម្បីស្វាគមន៍ព្រះយេស៊ូដែលចង់ជួបយើងនៅថ្ងៃណាមួយ។ ខ្ញុំនឹកឃើញមីងដែលពិការម្នាក់នៅព្រះសហគមន៍ស្វាយប៉ាកនេះ នៅមុនពេលគាត់ទទួលមរណៈភាពគាត់មានសុខភាពល្អធម្មតា។ ប៉ុន្តែ នៅក្នុងពេលវេលាខ្លីមួយ គាត់បានដាច់សរសៃឈាមខួរក្បាលណែនាំឲ្យគាត់ស្លាប់តែម្តង។ យើងដឹងថា គាត់ជាមនុស្សម្នាក់ដែលបានត្រៀមខ្លួនរាល់ថ្ងៃ គាត់បានអធិដ្ឋាន ចូលអភិបូជា គាត់បានត្រៀមខ្លួនជានិច្ច។

ពេលយើងនិយាយអំពីស្ត្រីដែលមានប្រាជ្ញា មានន័យថាជាស្ត្រីដែលពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ គ្រីស្តបរិស័ទយើងក៏ពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធដែរ។ នៅពេលយើងទទួលអគ្គសញ្ញាជ្រមុជទឹក យើងបានទទួលព្រះវិញ្ញាណដ៏វិសុទ្ធ នៅពេលយើងទទួលអគ្គសញ្ញាលាបថ្វាសក៏ព្រះវិញ្ញាណដ៏វិសុទ្ធនៅពេញលក្ខណៈ។ ពីមួយថ្ងៃទៅមួយថ្ងៃ ពេលយើងចូលអភិបូជា ពេលយើងអធិដ្ឋាន យើងដឹងថាព្រះវិញ្ញាណដ៏វិសុទ្ធយាងមក។ ព្រះវិញ្ញាណដ៏វិសុទ្ធយាងមកណែនាំឲ្យយើងមានជំនឿ ឲ្យយើងមានសេចក្តីស្រឡាញ់ ឲ្យយើងពោរពេញដោយសេចក្តីពិត ឲ្យយើងចេះលើកលែងទោសឲ្យគ្នា ឲ្យយើងចេះគោរពកោតសរសើរព្រះជាម្ចាស់នៅក្នុងការអធិដ្ឋាន

ជានិច្ច។ នេះជាសញ្ញានៃវត្តមាន របស់ព្រះវិញ្ញាណដ៏វិសុទ្ធនៅក្នុងជីវិតរបស់យើង ជំនឿ សេចក្តីស្រឡាញ់ សេចក្តីពិត ចិត្តស្លូតបូត ការលើកលែងទោស គោរពស្រឡាញ់ព្រះជាម្ចាស់ជានិច្ច។

នៅពេលនេះ ពិភពលោករបស់យើងកំពុងប្រែប្រួលអស់ហើយ ពិភពលោកកំពុងភ័យខ្លាច ពិភពលោកកំពុងធ្លាក់ចុះ ព្រោះមានអ្នកស្លាប់យ៉ាងច្រើនដោយសារជំងឺកូវីដ១៩ និងមានមនុស្សយ៉ាងច្រើនដែលបាត់បង់អ្វីៗទាំងអស់នៅក្នុងជីវិត។ ដោយសារកូវីដ១៩ ណែនាំឲ្យសេដ្ឋកិច្ចពិភពលោកធ្លាក់ចុះ នៅប្រទេសកម្ពុជាយើងក៏ចាប់ផ្តើមមានឥទ្ធិពលនៃជំងឺនេះខ្លាំងទៅៗដែរ។ ដូច្នេះ នេះជាពេលវេលាមួយដើម្បីឲ្យយើងភ្ញាក់ស្មារតី **តើយើងត្រូវធ្វើដូចម្តេចដើម្បីកសាងពិភពថ្មី? តើយើងត្រូវធ្វើដូចម្តេចដើម្បីសង្គមថ្មី?** សម្រាប់យើងដែលជាគ្រីស្តបរិស័ទ **តើយើងអាចចូលរួមយ៉ាងសកម្មនៅក្នុងជីវិតនៃសង្គមរបស់យើងទេ?** នៅក្នុងជីវិតនៃនយោបាយ នៅក្នុងជីវិតនៃសេដ្ឋកិច្ច នៅក្នុងជីវិតនៃវប្បធម៌ ដើម្បីឲ្យពន្លឺរបស់ព្រះគ្រីស្តអាចបំភ្លឺគ្រប់វិស័យនៅក្នុងសង្គម តាមរយៈជីវិតរបស់យើងជាគ្រីស្តបរិស័ទដែលផ្តល់សក្ខីភាព និងជាពិសេសដែលយើងរួមរស់ជាបងប្អូនបង្កើត។

ថ្មីៗនេះ សម្តេចប៉ាប **ហ្វ្រង់ស៊ីស្កូ** បានសរសេរសារលិខិតមួយ ដើម្បីណែនាំឲ្យពិភពលោកយើងគិតពិចារណា នៅលើផែនដីយើងជាគ្រួសារតែមួយ នៅលើផែនដីយើងជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់។ ពេលយើងនិយាយថាយើងជាគ្រួសារតែមួយ និងជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់ មានន័យថាប្រសិនបើយើងទទួលស្គាល់យើងជាបងប្អូនគ្នា ប្រសិនបើយើងទទួលស្គាល់យើងជាគ្រួសារតែមួយ **តើយើងធ្វើអ្វីខ្លះដើម្បីណែនាំឲ្យគម្រោងការរបស់ព្រះជាម្ចាស់ គឺបង្កើតព្រះរាជ្យរបស់ព្រះជាម្ចាស់លើផែនដីនេះអាចជាប់យ៉ាងពិតប្រាកដមែន?** នេះអាស្រ័យលើយើងដែលជាគ្រីស្តបរិស័ទ **តើយើងសុខចិត្តជួយគ្នាទៅវិញទៅមកឬទេ? តើយើងសុខចិត្តសាមគ្គីគ្នាឬទេ? តើយើងសុខចិត្តសន្ទនាគ្នា នៅក្នុងគណៈកម្មការព្រះសហគមន៍ នៅក្នុងគ្រួសារយើង នៅក្នុងភូមិយើង នៅក្នុងអន្តរសាសនាឬទេ?** សព្វថ្ងៃនៅក្នុងពិភពលោក កំពុងមានផ្ទុះសង្គ្រាមសាសនាជាច្រើនកន្លែង ដូច្នេះឲ្យយើងចេះសន្ទនាគ្នាជាមួយសាសនាដទៃ ដើម្បីបង្កើតសង្គមមួយដែលមានសុខដុមរមនា។ យើងមិននិយាយគ្នាតាមរយៈសារក្នុងទូរស័ព្ទដៃ ឬអ៊ីនធើណេត ឲ្យយើងនិយាយគ្នាផ្ទាល់មាត់ ដើម្បីឲ្យយើងសម្រុះសម្រួលគ្រប់បញ្ហា និងយល់ចិត្តគ្នាយ៉ាងពិតប្រាកដ។

កូវីដ១៩ ណែនាំឲ្យយើងភ័យខ្លាចជួបជុំគ្នា ភ័យខ្លាចបើកព្រំដែនប្រទេសនីមួយៗ ប៉ុន្តែកុំឲ្យការភ័យខ្លាចនេះទៅជាវប្បធម៌ថ្មី។ យើងអាចភ័យមួយរយៈពេល ដើម្បីប្រុងប្រយ័ត្នពិតមែន ដើម្បីឲ្យយើងយកចិត្តទុកដាក់ការពារខ្លួន ប៉ុន្តែឲ្យយើងប្រុងប្រយ័ត្នមែនទែនកុំឲ្យការភ័យខ្លាចនេះទៅជាវប្បធម៌ថ្មី។ វប្បធម៌ថ្មី ដែលណែនាំឲ្យយើងបិទទ្វារនៃប្រទេសនីមួយៗ បិទទ្វារនៃសង្គមនីមួយៗ បិទទ្វារនៃដួងចិត្តរបស់យើង។ ផ្ទុយទៅវិញ យើងត្រូវការនឹកឃើញដល់សម្តេចប៉ាប **យ៉ូហានប៉ូល**

**ទីពីរ** នៅពេលព្រះអង្គបានទទួលមុខងារជាសម្តេចប៉ាប បានទេសនាថា "**កុំខ្លាចអី! សូមបើកទ្វារ**" ដើម្បីទទួលស្វាគមន៍ព្រះយេស៊ូគ្រីស្ត។ ដោយសារ មានតែព្រះយេស៊ូគ្រីស្តដែលមានព្រះជន្មអស់កល្បជានិច្ច ដែលណែនាំឲ្យយើងមានសេចក្តីសុខនិងសុភមង្គល។ សម្រាប់យើងដែលជាគ្រីស្តបរិស័ទ យើងត្រូវការធ្វើប្រយ័ត្នមែនទែន កុំឲ្យយើងបង្កើតវប្បធម៌ថ្មីដែលជាវប្បធម៌ដែលណែនាំឲ្យយើងមានចិត្តគំនិតចង្អៀតចង្អល់ ដែលណែនាំឲ្យយើងបិទទ្វារនៃដួងចិត្តរបស់យើង ដើម្បីទៅជាមនុស្សអាត្មានិយម។ ពិភពលោករបស់យើង ជាពិភពដែលព្រះជាម្ចាស់ប្រទានឲ្យ ដូច្នេះឲ្យយើងមានចិត្តសាមគ្គី ឲ្យមានចិត្តស្រឡាញ់គ្នា សន្ទនារវាងគ្នានឹងគ្នា ដោយគោរពធម្មជាតិនិងអ្វីៗទាំងអស់ដែលព្រះជាម្ចាស់ប្រទានមក។

បីសប្តាហ៍ទៀត យើងចូលនៅក្នុងរដូវរង់ចាំ រង់ចាំព្រះយេស៊ូយាងមក រង់ចាំព្រះយេស៊ូប្រសូត។ ដូច្នេះ ខ្ញុំសូមឲ្យបងប្អូនគ្រីស្តបរិស័ទទាំងអស់នៅក្នុងភូមិភាគភ្នំពេញ ក្នុងរដូវរង់ចាំនេះយកចិត្តទុកដាក់ដើម្បីទុកឲ្យទ្វារនៃជីវិត ឲ្យទ្វារនៃសេចក្តីស្រឡាញ់បើកដើម្បីទទួលស្វាគមន៍មនុស្សទាំងអស់ ជាពិសេសដើម្បីទទួលស្វាគមន៍ព្រះយេស៊ូដែលកំពុងយាងមក។ យើងមិនដឹងថាព្រះយេស៊ូយាងមករបៀបណា ប៉ុន្តែយើងត្រៀមខ្លួនដើម្បីជួបជាមួយព្រះអង្គ ដែលយាងមកដើម្បីណែនាំឲ្យយើងមានជីវិត ណែនាំឲ្យយើងរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ នៅក្នុងសេចក្តីសុខសាន្តនិងនៅក្នុងសេចក្តីស្រឡាញ់។ យើងចាប់ផ្តើមប្រកាសដំណឹងល្អនៅកន្លែងថ្មី ដូច្នេះឲ្យយើងធ្វើដូចម្តេច ដើម្បីឲ្យការប្រកាសដំណឹងល្អរបស់យើងទៅជាសេចក្តីសង្ឃឹម សម្រាប់ប្រជារាស្ត្ររបស់យើង។ មូលហេតុដែលមានបងប្អូនថ្មីៗចង់ដើរតាមព្រះយេស៊ូ ព្រោះថាគេចង់រកឃើញផ្លូវជីវិតថ្មីសម្រាប់ពួកគាត់។ ដូចសន្តីម៉ារីម៉ាដាឡា ព្រះយេស៊ូបានណែនាំឲ្យគាត់មានជីវិតថ្មី គាត់ពោរពេញដោយអំណរសប្បាយ ដោយសារព្រះយេស៊ូបានបើកផ្លូវនៃជីវិតរបស់គាត់។ គាត់ជាមនុស្សមានទុក្ខលំបាក មានអំពើបាប គាត់យល់ថាព្រះយេស៊ូស្រឡាញ់គាត់ ដូច្នេះឲ្យយើងយល់ថាព្រះយេស៊ូស្រឡាញ់យើងដែរ យើងធ្វើដូចម្តេចដើម្បីឲ្យសេចក្តីស្រឡាញ់នេះទៅដល់បងប្អូនឯទៀតៗ។ ឲ្យយើងចូលនៅក្នុងជីវិតថ្មី នៅក្នុងវប្បធម៌ថ្មីនៃសតវត្សទី២១ គឺវប្បធម៌នៃធម៌មេត្តាករុណាដោយសារមានតែធម៌មេត្តាករុណាដែលអាចឈ្នះ។ ប្រសិនបើយើងមើលជីវិតនៃសន្តសន្តី បងប្អូនទាំងអស់មានឧបការីផ្ទាល់ខ្លួនមួយ ឲ្យយើងមើលជីវិតរបស់ពួកគាត់ **តើគាត់បានធ្វើដូចម្តេចដើម្បីភ្ជាប់ជាមួយព្រះជាម្ចាស់?** ឲ្យយើងខិតខំធ្វើតាម ដើម្បីរួមរស់នៅក្នុងជីវិតជាគ្រីស្តបរិស័ទដើរតាមព្រះយេស៊ូជានិច្ច។

យើងអធិដ្ឋានសម្រាប់គ្នាទៅវិញទៅមក ដើម្បីឲ្យយើងបង្កើតជីវិតថ្មី វប្បធម៌ថ្មី សង្គមថ្មី និងឲ្យយើងពិចារណា "**ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា សូមប្រុងស្មារតីព្បិតអ្នករាល់គ្នាពុំដឹងថា**

**បុត្រមនុស្សនឹងមកដល់ថ្ងៃណា ឬពេលណាឡើយ**"។ ឲ្យយើងជ្រើសរើស **តើយើងចូលនៅក្នុងក្រុមស្ត្រីដែលមានប្រាជ្ញា ឬយើងចូលនៅក្នុងក្រុមស្ត្រីដែលគ្មានប្រាជ្ញា?** ប្រាជ្ញាមកពីព្រះវិញ្ញាណដ៏វិសុទ្ធឲ្យយើងសម្រេចចិត្តដើម្បីឲ្យរដូវរង់ចាំដែលជិតមកដល់នេះ ទៅជាពេលវេលាពិសេសឲ្យយើងកែប្រែចិត្តគំនិត ដើម្បីស្វាគមន៍ព្រះយេស៊ូនៅក្នុងជីវិតយើង និងចែករំលែកដល់បងប្អូនឯទៀតៗ។ អាម៉ែន៕